## ការពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈ របស់ធនាគារអភិវឌ្ឍន៍អាស៊ីបានចាប់ផ្តើមហើយ

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កំពុងធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយលើគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈរបស់ខ្លួន (Public Communications Policy - PCP) ដែលបានទទួលការអនុម័តនៅក្នុងឆ្នាំ ២០០៥។ ការពិនិត្យឡើងវិញនេះ នឹងធ្វើឡើងដោយមានលក្ខណៈចូលរួមយ៉ាងទូលំទូលាយ ហើយភាគីដែលពាក់ព័ន្ធជាច្រើននៅក្នុងប្រទេសជាសមាជិករបស់ ADB នឹងត្រូវបានអញ្ជើញឱ្យផ្តល់ជាមតិយោបល់ផងដែរ។ គេរំពឹងថា ឯកសារគោលនយោបាយដែលកែសម្រួលហើយ នឹងផ្ញើរទៅកាន់ក្រុមប្រឹក្សាភិបាលរបស់ ADB សម្រាប់ពិនិត្យពិចារណានៅក្នុង ត្រីមាសទី ១ ឆ្នាំ ២០១១។

ADB អញ្ជើញសាធារណៈជនឱ្យផ្តល់មតិយោបល់លើ PCP បច្ចុប្បន្ន រហូតដល់ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១០។ មតិយោបល់ទាំងនេះនឹងត្រូវបានយកមកពិចារណា ក្នុងការរៀបចំពង្រាងគោលនយោបាយទី ១ ដែលបានកែសម្រួលរួចហើយ ហើយ ដែលនឹងត្រូវយកមកពិភាក្សា នៅក្នុងការពិគ្រោះយោបល់ជាសាធារណៈ ដែលនឹងរៀបចំឡើង ក្នុងប្រទេសជាសមាជិកជាច្រើន នៅក្នុងត្រីមាសទី ២ ឆ្នាំ ២០១០។ កាលវិភាគសម្រាប់ដំណើរការពិនិត្យឡើងវិញនេះមានភ្ជាប់មកជាមួយ។

PCP អំពាវនាវឱ្យមានទំនាក់ទំនងខាងក្រៅប្រកបដោយប្រសិទ្ធភាព និង បង្កើនលទ្ធភាពទទួលបានព័ត៌មាន។ គោលនយោបាយនេះមានមូលដ្ឋានលើការសន្មត់ជាមុន ដែលផ្តល់អាទិភាពលើការបង្ហាញព័ត៌មាន លើកលែងតែក្នុងករណីដែលមានមូលហេតុសំខាន់ ដែលមិនចង់ឱ្យមានការបង្ហាញព័ត៌មាន។ គោលនយោបាយនេះផ្តោតជាសំខាន់យ៉ាងខ្លាំងលើជនដែលរងផលប៉ះពាល់ និង ការអភិវឌ្ឍន៍ប្រកបដោយការចូលរួម។

ចាប់តាំងពីការអនុម័តលើ PCP នៅក្នុងឆ្នាំ ២០០៥ មក ADB បានបង្កើត និង ផ្សព្វផ្សាយជាសាធារណៈនូវការវាយតម្លៃប្រចាំឆ្នាំ ចំពោះរបាយការណ៍ស្តីពីការអនុវត្តគោលនយោបាយនេះ។ ដំណើរការពិនិត្យឡើងវិញនេះនឹងធានាយ៉ាងណាឱ្យ PCP ឆ្លុះបញ្ចាំងពីមេរៀនដែលទទួលបាន និង ការអភិវឌ្ឍន៍នានា នៅក្នុង ADB។ ដំណើរការនេះក៏នឹងផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធខាងក្រៅផ្តល់ជាមតិយោបល់ និង សំណូមពរ ដើម្បីបង្កើនប្រសិទ្ធភាពរបស់ PCP។